**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ : .090/19...អល/មជពស

# សេចក្តីជូនដំណឹង
## ស្តីពីការអញ្ជើញ
## ចូលរួមដេញថ្លៃការថែទាំបណ្តាញ និង ជួសជុលប្រព័ន្ធផ្គត់ផ្គង់ខ្យល់ត្រជាក់
BMS System ( HVAC, Chillers, Pumps, AHUs Ducting )
## ជូនមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល សំរាប់ឆ្នាំ ២០១៩

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/ សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល )ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យបានជ្រាបថា មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល នឹងដាក់ឲ្យដេញថ្លៃជាសាធារណៈដើម្បីជ្រើសរើសក្រុមហ៊ុនថែទាំបណ្តាញ និងជួសជុលប្រព័ន្ធផ្គត់ផ្គង់ខ្យល់ត្រជាក់ BMS System (HVAC, Chillers, Pumps, AHUs Ducting ) ជូនមជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល ។

មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/ សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ និងមានដាក់លក់នៅ **អង្គភាពលទ្ធកម្ម** មជ្ឈមណ្ឌលជាតិពិសោធន៍សុខាភិបាល អាគារលេខ 245H ផ្លូវជាតិលេខ 6A ភូមិគៀនឃ្លាំង សង្កាត់ព្រែកលៀប ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៩ តទៅរៀងរាល់ម៉ោងធ្វើការ (ទំនាក់ទំនងទូរស័ព្ទលេខៈ 023 432 169, 012 636 349 ) ។

កាលបរិច្ឆេទឈប់ទទួលសំណើដេញថ្លៃនៅវេលាម៉ោង ១០ព្រឹក ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ ។

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង ១០ព្រឹក ថ្ងៃទី ០៧ ខែ តុលា ឆ្នាំ ២០១៩ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នាឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់ ។

ក្រុមហ៊ុន/ សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ ។

ថ្ងៃព្រហស្បតិ៍ ៧កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ កញ្ញា ឆ្នាំ ២០១៩

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឱសថការី. ទេព-ភីឡា

ចម្លងជូន ÷
- អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- អង្គភាពប្រឆាំងអំពើពុករលួយ
- ឯកសារ កាលប្បវត្តិ